ផ្នែកកែទម្រង់រដ្ឋបាល និងហិរញ្ញវត្ថុ ផ្នែកពត៌មានវិទ្យា និងបរិក្ខាកែកាត់ការងារផ្សេងៗទៀត ព្រមទាំងសាងសង់អាគារថ្មីមួយខ្នងមានតំលៃប្រមាណ ៥០.០០០ ដុល្លារ-អាមេរិក ។

មាត្រា ២ .- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារ សាធារណៈ ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

អ៊ុង ហួត ហ៊ុន សែន

★★★

## II. ការិយាល័យក្រសួង

### ១. ទីស្តីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

### ១- ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨

**ប្រកាសលេខ ៨៨៤ ប្រក.សហវ.ពដ**

**ស្តីពីការបំពេញបន្ថែមលើការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ ឆ្នាំ ១៩៩៨**

*****

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ និងលេខជស/រកត/០៨៩៧/១៥៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ច្បាប់ ចុះថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ ១៩៩១ ស្តីពីការបង្កើតពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដែលប្រកាសឲ្យប្រើដោយក្រឹត្យលេខ ២៥ក្រ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ១៩៩១

- បានឃើញ ច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០១៩៩/០១ ចុះថ្ងៃទី០៩ ខែ មករា ឆ្នាំ ១៩៩៩
- បានឃើញ អនុក្រឹត្យលេខ ០៨ អនក្រ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩១ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ
- បានឃើញប្រកាសលេខ ៧៩៩ ប្រក.សហវ.ពដ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ១៩៩៩
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

**ប្រការ ១ :** តារាងឧបសម្ព័ន្ធទី១ ភ្ជាប់ជាមួយប្រកាសលេខ ៧៩៩ ប្រក.សហវ.ពដ ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីប្រាក់ពន្ធត្រូវកំណត់ចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានបំពេញបន្ថែមដូចមានភ្ជាប់ជាមួយប្រកាសនេះ ដើម្បីកំណត់ចំនួនប្រាក់ពន្ធចំពោះជលយាន ឬជលយានយន្តផ្លូវសមុទ្រ ។

**ប្រការ ២ :** ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

ហត្ថលេខា និង ត្រា

**គាត ឈន់**

★★★

## តារាងឧបសម្ព័ន្ធបំពេញបន្ថែម
## ស្តីពី
## ប្រាក់ពន្ធត្រូវកំណត់ចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ

ភ្ជាប់ជាមួយប្រកាសលេខ ៨៨៥ ប្រក.សហវ.ពដ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ឯកតា : រៀល

| ប្រភេទមធ្យោបាយដឹកជញ្ជូន និង យានជំនិះ | កំរិតប្រាក់ពន្ធសំរាប់១ឆ្នាំក្នុង១គ្រឿង |
|---|---|
| ជលយានា ឬ ជលយានយន្ត ផ្លូវសមុទ្រ : | |
| - ទូកដឹកអ្នកដំណើរបណ្តោយដល់ ២០ម៉ែត្រ | ១០០.០០០ |
| - ទូកដឹកអ្នកដំណើរបណ្តោយពី ២១ម៉ែត្រដល់៣០ម៉ែត្រ | ១៥០.០០០ |
| - ទូកដឹកទំនិញដល់ ១០០តោន | ២០០.០០០ |
| - ទូកនេសាទដែលមានកំលាំងសេះដល់ ៩សេះ | ១០.០០០ |
| - ទូកនេសាទដែលមានកំលាំងសេះពី ១០សេះដល់២០សេះ | ១៥.០០០ |
| - ទូកនេសាទដែលមានកំលាំងសេះពី ២១សេះដល់៥០សេះ | ២៥.០០០ |
| - ទូកនេសាទដែលមានកំលាំងសេះពី ៥១សេះដល់៩០សេះ | ៥០.០០០ |
| - ទូកនេសាទដែលមានកំលាំងសេះពី៩១សេះដល់១៥០សេះ | ៧០.០០០ |
| - ទូកនេសាទដែលមានកំលាំងសេះពី ១៥១សេះឡើងទៅ | ១០០.០០០ |
| - ទូកនេសាទម៉ាស៊ីនចំហៀង (ជើងបង្គង) ដល់ ១២សេះ | ១០.០០០ |
| -ទូកនេសាទម៉ាស៊ីនចំហៀង(ជើងបង្គង)ពី១៣សេះដល់៥០សេះ | ២០.០០០ |
| - ទូកនេសាទម៉ាស៊ីនចំហៀង (ជើងបង្គង) ពី ៥១សេះឡើងទៅ | ៥០.០០០ |

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

ពេញលេខា និង ត្រា

**គាត ឈន់**

*****